អាការក្រៅ និង ការពិត

សេរីការ

យើងឃើញថា របបផ្តាច់ការនៅស្រុកខ្មែរសព្វថ្ងៃ បើតាមសំដីពួកមនុស្សក្រាប[1] គឺមាន អាការក្រៅ (apparence) ជា របបដឹកនាំដោយយុត្តិធម៌ ព្រោះពួកគាត់តែងតែលើកច្បាប់មកសំអាងថាអ្វីដែលអាជ្ញាធរ ប្រព្រឹត្ត គឺសុទ្ធតែ ស្របនឹងច្បាប់ទាំងអស់។ អាស្រ័យហេតុនេះ បានជា លោក ហ៊ុន សែន គាត់និយាយថា នៅស្រុកខ្មែរ វាគ្មានវិបត្តិនយោបាយនិងគ្មានការរំលោភច្បាប់អ្វីនោះទេ។ សំដីនេះ ទុកជា អញ្ញវាទកម្ម[2] (détournement de la vérité) ព្រោះ របបដឹកនាំនោះ ព្ជរ យុត្តិធម៌ ជាយីហោ តែប្រើ អយុត្តិធម៌ ជាមធ្យោបាយ សំរាប់ដឹកនាំ។ ឧទាហរណ៍ មានជាក់ស្តែង គឺថា អាជ្ញាធរ ចាប់ឃាតការសម្លាប់ មហាបុរស កែម ឡី តែអាជ្ញាធរនោះឯង ជាអ្នករៀបចំធ្វើឃាត។ ឈ្លោះ ជួបសម្លាប់នោះ តាមពិត ជននោះ មុនដំបូង និយាយកកែកការថា ខ្លួនគេជួលឲសម្លាប់ តែ នគរបាលទេ ជាអ្នកស្រែក បញ្ជាក់ថា វាឈ្លោះ ជួបសម្លាប់ ដើម្បីកាន្ទ្បែសំដី ក្នុងគោលបំណងលាក់នូវការពិត។ ឃ្លាពាក្យ ជួលសម្លាប់ក៏បញ្ជៀសនូវពំនិតទៅជា ឈ្លោះ ជួបសម្លាប់ នោះឯង។

---

[1] មនុស្សក្រាប ; អ្នកនាំពាក្យ ក្នុងន័យជាមនុស្សខ្ជូចនិយាយឲរ៉ាតែចុះដុនដាប។

[2] អញ្ញវាទកម្ម ; ការបញ្ជៀសនៃការពិត។

អញ្ញារ៉ាទកម្ម ជាអត្តរស់នៃរបបផ្តាច់ការ មានប្រាកដមែនតាំងពីបុរាណកាល នៅលើលោកីយនេះ។ ដូចមានសរសេរ នៅក្នុងសៀវភៅ របស់ លោក ប្លាតុង មានចំណងជើងថា **សាធារណរដ្ឋ** លោក បានលើកយក យុត្តិធម៌ និង អយុត្តិធម៌ មកពិពណ៌នាយ៉ាងក្បោះក្បាយ ដែលយើងធ្វើសង្ខេបមួយឃ្លាយ៉ាងខ្លីថា៖ អ្នកដឹកនាំ ប្រើយុត្តិធម៌ មិនដែលមានបារម្ភនឹងអយុត្តិធម៌នោះឡើយ តែអ្នកដឹកនាំ ប្រើអយុត្តិធម៌វិញ តែងតែមាន បារម្ភជានិច្ចនឹងអយុត្តិធម៌ ព្រោះបើគេដឹងមារយាទខ្លួន វានឹងមានទុក្ខដល់អាត្មា។ គំនិតនេះ វាដូចគ្នានឹង អ្នកធ្វើបុណ្យ មិនខ្លាចទទួលផល(បុណ្យ) តែអ្នកធ្វើបាប រៀរចាក ទ្ធរផល(បាប)។ ត្រូវដឹងថា បុណ្យ និងបាបនោះ នឹងកាត់កងសងគ្នា ដូចបំណុលជំពាក់ ពុំបានទេ គឺថា បុណ្យ និងបាប មានដោយចំណែកប្លែកគ្នា។ អ្នកបានធ្វើបុណ្យច្រើនតទៅ នឹងបានសោយសុខជាមុន តែបើអ្នកបានធ្វើបាបច្រើនជាមុន អ្នកនោះទៅសោយទុក្ខជាមុនប៉ុណ្ណោះ។ ភ្ជានក្នុង ព្រះពុទ្ធឫញ្ញាត្ត ១កាត់សងគ្នា នោះទេ។

តាមអាការក្រៅ អយុត្តិធម៌ ហាក់បី ដូចជាវា មានប្រៀបលើយុត្តិធម៌ព្រោះវា មិនញញើតនឹង រឹបជាន់ទ្រព្យអ្នកដទៃ ដូចពួកឈ្មួញជួលដី មានច្បាប់សម្ជទាន អាចដុតផ្ទះកសិករ និងកាប់ព្រៃ ដឹកទៅលក់នៅស្រុកយួន។ ចំពោះឈ្មួញបែបនោះ អ្វីជា អត្ថប្រយោជន៍ គឺគេទុកជា អត្ត: (juste) ព្រោះ ជាឈ្មួញ ត្រូវតែរកចំណេញ ដូចគ្រូពេទ្យ ត្រូវតែព្យាបាលជម្ងឺ ដូច្នេះអ្វីជាអត្ត:

គឺជា អំពើល្អ។ ការណ៍នេះ ដែល លោក ហ៊ុន សែនគាត់ធ្វើអនុ
មានថា មុខងារគាត់ ជានាយករដ្ឋមន្ត្រី ត្រូវហាមទុកមុន នូវ
សេរីភាព ធ្វើបាតុកម្មដើម្បី រក្សាសន្តិភាព ដូច្នេះសេរីភាព
បញ្ចេញមតិ នៃប្រជាជន ចំពោះគាត់ ជា អយុត្ត (injuste) ព្រោះ
គាត់ទុកមុខងាររបស់គាត់ជា អត្ត: គឺថាអំពើអ្វី ដែលគាត់ធ្វើ
នៅក្នុងមុខងារ វាជាយុត្តិធម៌ ហើយអ្វីដែលជា អយុត្តិធម៌ ប្រើ
តុលាការ សំរាប់ការពារ គឺជា យុត្តិធម៌។ ការមានប្រៀប អ
យុត្តិធម៌ លើយុត្តិធម៌បែបនេះ វាគ្រាន់តែជា អាការក្រៅតែ
ប៉ុណ្ណោះ ព្រោះ ការពិត វាផ្សេងទៅវិញ ដ្បិត សច្ច:សតិ (vérité
spirituelle) របស់អ្នកប្រព្រឹត្តិបែបនេះ វាគ្រាន់តែជា គុណកថា
(discours sur la vertu) សំរាប់បិទបាំងចិត្តអាក្រក់របស់ខ្លួន។ ការពិត
អយុត្តិធម៌ មិនដែលនាំ នូវសេចក្ដីសុខដល់អ្នកដទៃណាមួយ
ឡើយ ព្រោះ វាមានតម្លៃក្នុងនឹងក្រៅរបស់វា ជាអវិជ្ជមាន គឺ
ថា ជាតម្លៃដែលព្យាបាទ (ចង្រៃ) ដល់អ្នកដទៃ ដែលផ្ទុយស្រឡះ
ពីអ្នកប្រព្រឹត្តិយុត្តិធម៌ គេមាន បុញ្ញកិរិយា (fondement de la
vertu) ជាគុណសម្បត្តិ។ សម័យ ពន្លឺ នៃបញ្ញា និង ការជឿន
លឿន នៃព័ត៌មានសាស្ត្រសព្វថ្ងៃនេះ ធ្វើ១ អយុត្តិធម៌ មិនអាច
មាន អាការក្រៅ ជា យុត្តិធម៌ បាននោះទេ ព្រោះ ការពិត ជា
ចង្រៃរបស់វា ដែលវាមិនអាចលាក់បាំងនឹងប្រជានិការ បាន
ដូចសម័យដើមនោះឡើយ។ ពួកអ្នកដឹកនាំ និងឧកញ្ញាសព្វថ្ងៃ
បំបាន ក្លាយខ្លួនជា មហាសេដ្ឋី តែវាមិនមែនជាការបង្ហាញពី
ប្រៀប នៃអយុត្តិធម៌ លើយុត្តិធម៌នោះដែរ ព្រោះទ្រព្យ បានពី
ប្រវ័ញ្ចជាតិ និងអ្នកដទៃ គឺជាធនធានដ៏អសុរោះ ដែលនរណា

ក៏គេដឹង ហើយ គេគ្មាន កោតគោរពអ្វីនោះឡើយ។ ការណ៍នេះ ឯង ដែលជាការបញ្ជាក់ថា អយុត្តិធម៌ វាគ្មានប្រៀបអ្វី លើ យុត្តិធម៌បានទេ ព្រោះថា ការពិត វាបង្ហាញជាក់ស្តែង អំពីភាព ខុសសីលធម៌ នៃអំពើទុច្ចរិត ដែល ពួកជនលាមក ឬ ទុយ៌ស ទាំងឡាយនោះ កំពុង ប្រព្រឹត្តចាក់ផ្ទែរទៅរកកំហុស ដែលឲទុក្ខ ដល់ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ។